Media Release

Cambodia • Lao PDR • Thailand • Viet Nam
For sustainable development

សម្រាប់ការចេញផ្សាយបន្ទាន់

# សន្និសីទអន្តរជាតិផ្តល់អនុសាសន៍លើអាទិភាពមួយចំនួន សម្រាប់ឱ្យប្រទេសនៅតំបន់មេគង្គផ្នែកខាងក្រោម សម្រេចរបៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាព

**ខេត្តសៀមរាប ប្រទេសកម្ពុជា ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៨**—សន្និសីទអន្តរជាតិរយៈពេលពីរថ្ងៃ រៀបចំដោយគណៈកម្មការទន្លេមេគង្គ ត្រូវបានបិទបញ្ចប់ នៅថ្ងៃនេះ។ កិច្ចប្រជុំនេះ ជាការជួបជុំដ៏ធំជាងគេមួយមិនធ្លាប់ត្រូវបានរៀបចំឡើងដោយ MRC ដែលមានការចូលរួមពីអ្នកពាក់ព័ន្ធប្រមាណជា ៤០០ នាក់ មកពីរដ្ឋាភិបាលនៃប្រទេសជាប់ទន្លេមេគង្គ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នសិក្សាស្រាវជ្រាវ វិស័យឯកជន និងអង្គការអាងទន្លេដទៃទៀត។ អ្នកចូលរួមក្នុងកិច្ចប្រជុំនេះ បានដាក់ចេញនូវអនុសាសន៍រួមគ្នាមួយ សម្រាប់លើកកម្ពស់កិច្ចខិតខំប្រឹងប្រែងរួមគ្នា និងភាពជាដៃគូ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព នៅក្នុងតំបន់នេះ។

ឯកឧត្តម លឹម គានហោ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧត្តុនិយម និង សមាជិកក្រុមប្រឹក្សារបស់ MRC សម្រាប់ប្រទេសកម្ពុជា មានប្រសាសន៍ក្នុងពិធីបើកសន្និសីទនេះកាលពីថ្ងៃ ច័ន្ទ ថា "ចាំបាច់ត្រូវមានការធ្វើការងារ និងការរួមកម្លាំងគ្នាពីតួអង្គពាក់ព័ន្ធនានា សមត្ថភាព ទស្សនៈវិស័យ ការតម្រឹមការរួមចំណែករបស់យើងឱ្យមានទិសដៅស្របគ្នា និង ការជំរុញឱ្យមានការកសាងភាពជាដៃគូប្រកបដោយអត្ថន័យ ទើបយើងអាចបង្កើនឱកាស និងឆ្លើយតបចំពោះបញ្ហាប្រឈមនានានៅក្នុងតំបន់អាងទន្លេមេគង្គបាន ខណៈពេលដែលយើងបន្តដំណើររបស់យើងទៅមុខទៀត"។

អ្នកចូលរួមសន្និសីទបានវាយតំលៃខ្ពស់ ដល់កិច្ចខិតខំប្រឹងប្រែងរួមគ្នា និងភាពជាដៃគូ ដែលជាគោលការណ៍គន្លឹះនៃការគ្រប់ការងារទាំងអស់របស់គណៈកម្មការទន្លេមេគង្គ រាប់ចេញពីការរៀបចំ និងការអនុវត្តគោលការណ៍ណែនាំ យុទ្ធសាស្ត្រ និងនីតិវិធី រហូតដល់ការពិនិត្យតាមដានរួមគ្នា ការវាយតម្លៃ និងការរៀបចំរបាយការណ៍ស្តីពីស្ថានភាពអាងទន្លេនេះ ក៏ដូចជា ការធ្វើការជាមួយដៃគូ និងអ្នកពាក់ព័ន្ធដទៃទៀត។

កិច្ចខិតខំប្រឹងប្រែងរួមគ្នាទាំងនេះ ផ្តល់ការគាំទ្រដល់ប្រទេសជាសមាជិកទាំងអស់ មិនត្រឹមតែជួយសម្រេចឲ្យបាននូវការប្តេជ្ញាចិត្តរបស់ជាតិលើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៦ ស្តីពីទឹកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ពាក់ព័ន្ធនឹងភាពក្រីក្រ គ្រោះអត់ឃ្លាន យេនឌ័រ ថាមពល ហេដ្ឋារចនាសម្ព័ន្ធ ការប្រែប្រួលអាកាសធាតុ បរិស្ថាន សន្តិភាព និង

ស្ថាប័ន និងភាពជាដៃគូផងដែរ នេះបើតាមសេចក្តីសន្និដ្ឋានរបស់អ្នកចូលរួមក្នុងសន្និសីទនេះ។ គណៈកម្មការទន្លេមេគង្គ ទទួលស្គាល់ពីតួនាទីដ៏សំខាន់ ដែលការអភិវឌ្ឍ និងការគ្រប់គ្រងធនធានទឹក និងធនធានពាក់ព័ន្ធនានាមានចំពោះការសម្រេចការអភិវឌ្ឍន៍ប្រកបដោយចីរភាព ហើយគណៈកម្មការនេះខិតខំផ្តល់ភស្តុតាង ដើម្បីជួយឱ្យការសម្រេចិត្ត និងកិច្ចសហប្រតិបត្តិការកាន់តែមានលក្ខណៈល្អប្រសើរជាងមុន សំដៅគាំទ្រដល់បណ្តាប្រទេសក្នុងតំបន់ទន្លេមេគង្គនេះ ខណៈពេលដែលប្រទេសទាំងនេះកំពុងធ្វើការសម្រេចចិត្តអំពីភាពទ្វេគ្រោះ (ជម្រើសរវាងការខាតបង់ និងអត្ថប្រយោជន៍) និងរបៀបធ្វើការងាររួមគ្នា ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ឧទាហរណ៍ អ្នកចូលរួមនៅក្នុងសន្និសីទនេះយល់ឃើញថា ការសិក្សាស្តីពីការគ្រប់គ្រងទន្លេមេគង្គប្រកបដោយចីរភាព ដែលចំណាយពេលប្រាំមួយឆ្នាំ ហើយដែលគណៈកម្មការទន្លេមេគង្គ ទើបតែបញ្ចប់កាលពីពេលថ្មីៗនេះ បានបង្ហាញពីព័ត៌មានវិទ្យាសាស្ត្រសំខាន់ៗជាច្រើន សម្រាប់ណែនាំដល់ការតាក់តែងគោលនយោបាយ ហើយទន្ទឹមគ្នានេះការសិក្សានេះក៏លើកឡើងពីចំណុចខ្វះខាតផងដែរ។

លទ្ធផលនៃការសិក្សានេះបង្ហាញឱ្យឃើញពីអត្ថប្រយោជន៍ជាវិជ្ជមានផង និងផលប៉ះពាល់ជាអវិជ្ជមានផង ចេញពីការអភិវឌ្ឍគ្រោងនឹងធ្វើឡើង។ ការឆ្លើយតបចំពោះផលប៉ះពាល់អវិជ្ជមានឆ្លងដែនទាំងនេះ ទាមទារឱ្យមានការខិតខំប្រឹងប្រែងរួមគ្នាខ្លាំងជាងមុន ដូចជា ការរៀបចំផែនការ និងគម្រោងឱ្យបានល្អបំផុត ដើម្បីសម្រេចនូវអត្ថប្រយោជន៍ឱ្យបានច្រើនបំផុត និងកាត់បន្ថយការខាតបង់នានាឱ្យតិចតួចបំផុត រៀបចំឲ្យមានវិធានការណ៍កាត់បន្ថយផលប៉ះពាល់ និងធ្វើការវាយតម្លៃពីជម្រើសផ្សេងទៀតសម្រាប់រៀបចំគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដែលឆ្លើយតបចំពោះបញ្ហាសន្តិសុខទឹក-ស្បៀង-ថាមពល និងគម្រោងទាំងឡាយណាដែលប្រទេសក្នុងតំបន់មេគង្គ-ឡានឆាង អាចផ្តល់ហិរញ្ញប្បទាន និងមានភាពជាម្ចាស់រួមគ្នាបាន។

ចុងក្រោយ ស្របគ្នានឹងការផ្តោតការយកចិត្តទុកដាក់លើការពង្រឹងភាពជាដៃគូ នៅក្នុងសន្និសីទអន្តរជាតិនេះ ក៏មានការចុះហត្ថលេខាលើអនុស្សរណៈព្រមព្រៀងចំនួនពីរ រវាងគណៈកម្មការទន្លេមេគង្គ និងគណៈកម្មការសង្គមកិច្ច និងសេដ្ឋកិច្ចសហប្រជាជាតិសម្រាប់អាស៊ីប៉ាស៊ីហ្វិក (ESCAP) និងការិយាល័យសហប្រជាជាតិសម្រាប់សេវាគម្រោង (UNOPS) ផងដែរ។ គណៈកម្មការទន្លេមេគង្គ នឹងសហការជាមួយ ESCAP ដើម្បីកំណត់ និងវាយតម្លៃហានិភ័យគ្រោះមហន្តរាយ កាត់បន្ថយហានិភ័យទាំងនេះ និងត្រៀមរៀបចំ ដើម្បីធ្វើការឆ្លើយតបប្រកបដោយប្រសិទ្ធភាព ចំពោះស្ថានភាពគ្រោះមហន្តរាយនានា ដូចជាគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតជាដើម។ ដោយឡែកចំពោះកិច្ចព្រមព្រៀងជាមួយ UNOPS គណៈកម្មការទន្លេមេគង្គ នឹងទទួលបានអត្ថប្រយោជន៍ពីសេវាកម្មផ្នែកលទ្ធកម្ម និងការស្វែងរកជំនួយសម្រាប់គម្រោងទាំងឡាយក្នុងអាងទន្លេមេគង្គ ជាដើម។

សារសំខាន់ៗ និងអនុសាសន៍ចេញពីសន្និសីទអន្តរជាតិនេះ នឹងបញ្ជូនទៅកាន់កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីរបស់គណៈកម្មការទន្លេមេគង្គ ដែលនឹងចាប់ផ្តើមធ្វើឡើងនៅថ្ងៃស្អែក ពេលគឺថ្ងៃទី ៤ ខែ មេសា

ឆ្នាំ ២០១៨ និងកិច្ចប្រជុំកំពូលគណៈកម្មការទន្លេមេគង្គលើកទី ៣ ដែលមានការចូលរួមពីប្រមុខរដ្ឋាភិបាលមកពីប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ និងដៃគូសន្ទនានានា នៅថ្ងៃព្រហស្បតិ៍ ទី ៥ ខែ មេសា ឆ្នាំ ២០១៨ ក្នុងខេត្តសៀមរាប ប្រទេសកម្ពុជា។

**កំណត់សម្គាល់ចំពោះនិពន្ធនាយកៈ**

គណៈកម្មការទន្លេមេគង្គ គឺជាស្ថាប័នអន្តររដ្ឋាភិបាលដែលមានតួនាទីជំរុញ លើកកម្ពស់កិច្ចពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ក្នុងអាងទន្លេមេគង្គខ្សែទឹកខាងក្រោម ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ផ្អែកទៅតាមកិច្ចព្រមព្រៀងទន្លេមេគង្គរវាងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ ស្ថាប័ននេះបំពេញតួនាទីជាវេទិកាថ្នាក់តំបន់សម្រាប់កាទូតផ្នែកទឹក ក៏ដូចជាមជ្ឈមណ្ឌលចំណេះដឹងស្តីពីការគ្រប់គ្រងធនធានទឹក ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពរបស់តំបន់នេះ។

- **ចប់** -

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងៈ**

លោក មាស សុភក្ត្រ
មន្ត្រីទំនាក់ទំនងស្តីទីសម្រាប់អ្នកសារព័ត៌មាន
លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ
អ៊ីម៉ែល: sopheak@mrcmekong.org
ទូរសព្ទ: +855-12-266653